ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៤៨៤៨......អពដ

ថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៩

# សេចក្តីណែនាំ
# ស្តីពី
# ការកំណត់ឯកសារភស្តុតាងបញ្ជាក់ការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់ នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យភាគរយ

អនុលោមតាមមាត្រា ៤៥ និងមាត្រា ៥៤ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម ការផ្គត់ផ្គង់សេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា គឺត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ ហើយដែនអនុវត្តនៃបទប្បញ្ញត្តិនេះត្រូវរួមបញ្ចូលផងដែរនូវការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់ នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលមាន**ឯកសារភស្តុតាងគ្រប់គ្រាន់សម្រាប់អគ្គនាយកដ្ឋានពន្ធដារពិនិត្យនិងសំរេច។**

ហេតុនេះ អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំអំពីការគិតអាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ ចំពោះការផ្គត់ផ្គង់សេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា និងការផ្គត់ផ្គង់សេវាសម្រាប់ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម÷

## ១. ចំពោះការផ្គត់ផ្គង់សេវាដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា

ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជា លុះត្រាតែសេវានោះបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដោយសហគ្រាសនិវាសនជននៅកម្ពុជា។ ការបំពេញសេវានៅក្រៅព្រះរាជាណាចក្រកម្ពុជានេះ អាចធ្វើឡើងដោយសហគ្រាសនិវាសនជនកម្ពុជា តាមរយៈការបញ្ជូនទៅ និង/ឬប្រើប្រាស់បុគ្គលិក ឬអ្នកបច្ចេកទេស ក្រៅព្រះរាជាណាចក្រកម្ពុជា សម្រាប់បំពេញការងារនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

**ឧទាហរណ៍÷** សហគ្រាស **ក** (និវាសនជនកម្ពុជា) បញ្ជូនបុគ្គលិក ឬអ្នកបច្ចេកទេសពីកម្ពុជា ឬជួលបុគ្គលិក ឬអ្នកបច្ចេកទេស នៅក្រៅព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្គត់ផ្គង់សេវា ដូចជា ទីប្រឹក្សាផ្តល់យោបល់ផ្នែក ច្បាប់ គណនេយ្យ សារពើពន្ធ ពាណិជ្ជកម្ម សិក្សាស្រាវជ្រាវ ឬវិភាគទិន្នន័យផ្សេងៗ ។ល។ ដល់បុគ្គលអនិវាសនជន នៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ការផ្គត់ផ្គង់សេវានេះ ត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ។

## ២. ចំពោះការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា

ក. ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា លុះត្រាតែសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយសហគ្រាសនិវាសនជនកម្ពុជា និងសម្រាប់គោលដៅការប្រើប្រាស់ផ្ទាល់និងដាច់ខាតនៅក្រៅព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលអនិវាសនជន។

ខ. អ្នកជាប់ពន្ធនិវាសនជន ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធលើទឹកប្រាក់អាករលើតម្លៃបន្ថែម ដែលបុគ្គលនេះបានសម្រេចអនុវត្តអាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ ដោយមូលហេតុខ្លួនបានកំណត់ថា ការផ្គត់ផ្គង់សេវាបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌ ក ចំណុច២ នៃសេចក្តីណែនាំនេះ។



អគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

**ឧទាហរណ៍**÷ សហគ្រាស ក (និវាសនជនកម្ពុជា) បានផ្តល់សេវាគូរប្លង់សាងសង់អគារទំនើប សរសេរកម្មវិធីសូហ្វែរ ឬបទនិពន្ធផ្សេងៗ ឱ្យសហគ្រាស ខ នៅក្រៅព្រះរាជាណាចក្រកម្ពុជា។ សហគ្រាស ក ត្រូវបានចាត់ទុកថា បានបំពេញសេវា សម្រាប់ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា លុះត្រាតែសហគ្រាស ខ យកប្លង់សាងសង់អគារទំនើប កម្មវិធីសូហ្វែរ ឬបទនិពន្ធផ្សេងៗនោះ ទៅប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា និងត្រូវមានឯកសារភស្តុតាងដូចមានបញ្ជាក់ក្នុងចំណុច៣ ខាងក្រោម។ ការផ្គត់ផ្គង់សេវាទាំងនេះ ត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ។

គ. ការផ្គត់ផ្គង់សេវាមិនត្រូវចាត់ទុកថាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជាទេ ក្នុងករណីសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយសហគ្រាសនិវាសនជនកម្ពុជា ហើយត្រូវបានបុគ្គលអនិវាសនជនកម្ពុជាប្រើប្រាស់សម្រាប់គោលដៅអាជីវកម្ម ឬផលប្រយោជន៍សេដ្ឋកិច្ចណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងពេលវេលាណាមួយ។

**ឧទាហរណ៍ទី១**÷ សហគ្រាស ក (និវាសនជនកម្ពុជា) បានផ្តល់សេវាផ្តល់ប្រឹក្សាយោបល់នានាដូចជាច្បាប់ គណនេយ្យ សារពើពន្ធ ពាណិជ្ជកម្ម សិក្សាស្រាវជ្រាវ ឬវិភាគទិន្នន័យផ្សេងៗ ។ល។ ដែលទាក់ទងនឹងប្រទេសកម្ពុជា ឱ្យសហគ្រាស ខ នៅក្រៅព្រះរាជាណាចក្រកម្ពុជា។ សហគ្រាស ក ត្រូវបានចាត់ទុកថា បានបំពេញសេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រោះសេវានោះនឹងត្រូវបានយកមកប្រើប្រាស់សម្រាប់គោលដៅអាជីវកម្ម ឬផលប្រយោជន៍សេដ្ឋកិច្ចណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការផ្គត់ផ្គង់សេវានេះ ត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រា ១០ភាគរយ។

**ឧទាហរណ៍ទី២**÷ សហគ្រាស ក (និវាសនជនកម្ពុជា) បានផ្តល់សេវាវិភាគឬពិនិត្យគុណភាពទំនិញដើម្បីធ្វើការនាំចេញទំនិញពីព្រះរាជាណាចក្រកម្ពុជាឱ្យសហគ្រាស ខ នៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ សេវានេះត្រូវបានបំពេញ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជារួចហើយ ទើបនាំឱ្យមានការសម្រេចបញ្ជូនទំនិញចេញពីព្រះរាជាណាចក្រកម្ពុជា។ ការផ្គត់ផ្គង់សេវានេះ ត្រូវជាប់អាករលើតម្លៃបន្ថែម តាមអត្រា ១០ភាគរយ។

**៣. ឯកសារភស្តុតាងចំពោះការផ្គត់ផ្គង់សេវាសម្រាប់ការប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា**

ដើម្បីទទួលបានអាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ ត្រូវមានឯកសារភស្តុតាងបញ្ជាក់ ដូចខាងក្រោម÷

ក. កិច្ចសន្យាដែលត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកម្រៃសេវា ប្រភេទសេវា និងទីកន្លែងដែលត្រូវបំពេញសេវា

ខ. ឯកសារទូទាត់ប្រាក់ពីក្រៅព្រះរាជាណាចក្រកម្ពុជា មកធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា

គ. វិក្កយបត្រច្បាប់ដើម

ឃ.ឯកសារគណនេយ្យដែលអាចត្រួតពិនិត្យបាន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សហគ្រាសទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**